00366497

D164/4/5

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 24 / 08 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**<u>ព័ត៌មានពិស្ដារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស-អ.ប.ជ ២៤

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: បារាំង

កាលបរិច្ឆេទឯកសារ: ២៤ សីហា ២០០៩

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 25 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA. [signature]

---

## គោលជំហររបស់ក្រុមការពារក្ដីលើការទទួលយកបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹង “ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងបញ្ជីឯកសាររួម”

---

<u>ដាក់ដោយ</u>៖

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សុវាន

លោក Jacques VERGÈS

<u>ផ្ញើរជូន</u>៖

**អង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

---

**សហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង**

**ដើមបណ្តឹងរដ្ឋប្បវេណីមិនមានតំណាងទាំងអស់**

00366499



# គោរពជូនអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

១. តាមសេចក្តីសម្រេច ចុះថ្ងៃទី២០ សីហា ២០០៩ អង្គបុរេជំនុំជម្រះបានសម្រេចថា នឹងមិនបើកសវនាការសួរជំនុំជម្រះលើ "បណ្តឹងឧទ្ធរណ៍រួមរបស់ក្រុមការពារក្តី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៩ មិថុនា ២០០៩ លើសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងបញ្ជីឯកសាររួម"[1] ដូចដែលសហមេធាវីការពារក្តីរបស់លោកស្រី អៀង ធិរិទ្ធ លោក នួន ជា និងលោក ខៀវ សំផន បានទាមទារនោះទេ។ ដូច្នេះ អង្គបុរេជំនុំជម្រះបង្គាប់ឲ្យសហមេធាវីការពារក្តីជនត្រូវចោទដាក់សារណាតបជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងមាត្រា៨.៤នៃសេចក្តីណែនាំអនុវត្តអ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៤[2]។

២. សហមេធាវីការពារក្តីលោក ខៀវ សំផន បានដាក់ជូនសំណើសុំឲ្យពិចារណាឡើងវិញលើសេចក្តីសម្រេចនេះ និងពិនិត្យលទ្ធភាពជាថ្មីម្តងទៀតក្នុងការឲ្យមានសវនាការជំនុំជម្រះមួយ។ សំណើសុំនេះត្រូវបានដាក់នៅថ្ងៃនេះ ក្នុងថេរវេលាដែលបានកំណត់ក្នុងសេចក្តីណែនាំអនុវត្ត[3] យោងតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងទោះក្នុងកាលៈទេសៈណា សហមេធាវីការពារក្តីសូមរក្សាសិទ្ធិឆ្លើយតបទៅនឹងចម្លើយរបស់ សហព្រះរាជអាជ្ញាលើបញ្ហាអង្គហេតុ។

---

[1] សារណាបណ្តឹងឧទ្ធរណ៍រួមគ្នារបស់ក្រុមការពារក្តី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបងង្កេតចុះថ្ងៃទី១៩ មិថុនា២០០៩ ទាក់ទងនឹងសំណើសុំស្វែងរកភស្តុតាង ដោះបន្ទុកនៅក្នុងបញ្ជីទុកឯកសាររួម ថ្ងៃទី២៤ កក្កដា ២០០៩ ឯកសារតុលាការ D164/4/1 (តទៅនេះ ហៅថា "សារណាបណ្តឹងឧទ្ធរណ៍ក្រុមការពារក្តី")

[2] សេចក្តីសម្រេចលើសំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និងអបជ២៥ ថ្ងៃទី ២០ សីហា ២០០៩ ឯកសារតុលាការ D164/4/3 (តទៅនេះ ហៅថា "សេចក្តីសម្រេច")

[3] ពាក្យសុំឲ្យពិចារណាឡើងវិញលើ "សេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការ សួរដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និងអបជ២៥ ថ្ងៃទី២៤ សីហា២០០៩ មិនទាន់មានលេខយោង
គោលជំហរក្រុមការពារក្តីលើការទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង"ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាង ដោះបន្ទុកនៅក្នុងបញ្ជីឯកសាររួម"

៣. នៅពេលនេះ ពួកយើងសូមឆ្លើយទៅនឹងមតិរបស់សហព្រះរាជអាជ្ញាអំពីការទទួលយកបណ្តឹងឧទ្ធរណ៍នេះ[4] ដូចដែលអង្គបុរេជំនុំជម្រះបានណែនាំពួកយើង។ ដូច្នេះ វាជាបញ្ហាចាំបាច់មុននឹងពិនិត្យលើអង្គហេតុផ្សេងទៀត ដែលមិនមានឧប្បត្តិហេតុលើប្រភេទនៃនីតិវិធីណាមួយទេ។

៤. ដោយសារហេតុផលថិរវេលាដែលបានកំណត់ សហមេធាវីសូមមិនរំលឹកឡើងវិញអំពីអង្គហេតុ ឬនីតិវិធីទេ។ ពួកយើងសូមលើកឡើងតែអំពីយោបល់របស់សហព្រះរាជអាជ្ញា និងចម្លើយតបរបស់ពួកយើងតែប៉ុណ្ណោះ។

៥. ក្នុងចម្លើយរបស់សហព្រះរាជអាជ្ញា ដែលមិនមានគោលជំហរពិតប្រាកដនោះ សហព្រះរាជអាជ្ញាបានលើកឡើងជាយោបល់សុំថា "ទៅអង្គបុរេជំនុំជម្រះឱ្យសន្និដ្ឋានថា លោក ខៀវ សំផន មិនអាចប្តឹងឧទ្ធរណ៍បានទេ ព្រោះ គាត់មិនមែនជាភាគីដែលដាក់ពាក្យសុំពីដំបូង ហើយដែលអាចថា គាត់មិនជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងដីកាសម្រេចនោះទេ"[5]។

៦. នេះជាយោបល់ដែលមិនមានមូលដ្ឋានត្រឹមត្រូវតាមច្បាប់ ហើយភ័ន្តច្រឡំ។លោក ខៀវ សំផន មានសិទ្ធិធ្វើវាល់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកាសម្រេចទាំងអស់ ដែលបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរណាមួយ ហើយសិទ្ធិរបស់គាត់ត្រូវតែអាចអនុវត្តបានយ៉ាងពេញលេញ និងដោយសេរី។ ទោះក្នុងករណីណាក៏ដោយ គាត់ជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនេះ ហើយ ដូច្នេះ បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន គឺត្រូវតែអាចទទួលយក និងមិនអាចជំទាស់បានឡើយ។

---

[4] សេចក្តីសម្រេចលើសំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និងអបជ២៥ ថ្ងៃទី២០ សីហា ២០០៩ ឯកសារតុលាការ D164/4/3 កថាខណ្ឌទី៧។

[5] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធិរិទ្ធ នួន ជា ខៀវ សំផន និងអៀង សារី ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ ថ្ងៃទី១០ សីហា ២០០៩ ឯកសារតុលាការ D164/4/2 (បន្ទាប់ទៅនេះហៅថា "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ៨។

00366501



## II. អត្ថបទច្បាប់សំខាន់ៗ

៧. ដូចដែលសហព្រះរាជអាជ្ញាបានរំលឹកឡើងវិញថា "វិធាន ៥៥.១០ នៃបទបញ្ជាផ្ទៃក្នុង ចែងថា ដីកាសម្រេចបដិសេធលើបណ្តាពាក្យសុំឱ្យស៊ើបអង្កេតត្រូវតែផ្តល់ដំណឹងឱ្យភាគី ហើយត្រូវតែអាចប្តឹងឧទ្ធរណ៍បាន"។ វិធាន៧៤ "អនុញ្ញាតម្យ៉ាងទៀតដល់ភាគីទាំងអស់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចចូលក្នុងវិស័យនេះ"[6]។

## III. យោបល់

**ក- លោក ខៀវ សំផន មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកាសម្រេចទាំងអស់ដែលបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ**

១- លោក ខៀវ សំផន មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកាសម្រេចតែមួយចំនួន

៨. ផ្ទុយនឹងសហព្រះរាជអាជ្ញាដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បានលើរាល់ដីកា ក្នុងរយៈពេលអង្កេតស៊ើបសួរ ជនត្រូវចោទមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ តែសិទ្ធិនោះត្រូវមានព្រំដែន។ វិធាន ៧៤ បានផ្តល់នូវបញ្ជីនៃឈ្មោះដីកាដែលជនត្រូវចោទអាចប្តឹងឧទ្ធរណ៍បាន ហើយបញ្ជីនេះត្រូវបានចាត់ទុកថាមានលក្ខណៈទាំងស្រុង[7]។ ដូច្នេះ លោក ខៀវ សំផន មានសិទ្ធិប្តឹងឧទ្ធរណ៍ដោយមានកម្រិត។

២- លោក ខៀវ សំផន មានសិទ្ធិគ្មានព្រំដែន ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកាសម្រេច បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ

៩. វិធាន ៧៤ នៃវិធានផ្ទៃក្នុងមានលក្ខណៈច្បាស់លាស់បំផុត។ វិធាននេះអនុញ្ញាតឱ្យ និងតាមពាក្យរបស់សហព្រះរាជអាជ្ញា "ភាគីណាក៏បានធ្វើបណ្តឹងឧទ្ធរណ៍លើគ្រប់ដីការសម្រេចបដិសេធនៃ

---

[6] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៨។ ដូចគ្នាដែរ សូមមើល មាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[7] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោកខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ កថាខណ្ឌ៣៣។

សំណើសុំកិច្ចស៊ើបសួរ"[8]។ វិធាន ៧៤ មិនមានចែងអំពីលក្ខខណ្ឌណាមួយលើសិទ្ធិប្តឹងឧទ្ធរណ៍នេះឡើយ។ សម្រាប់ដីកាសម្រេចប្រភេទនេះ គុណសម្បត្តិ ឬភាពជាជនត្រូវចោទត្រូវបានច្បាប់សន្មតថា មានប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍នេះ។

១០.ប៉ុន្តែ សហព្រះរាជអាជ្ញាបែរជាយល់ឃើញថា "វិធាន ៧៤ មិនមានបំណងផ្តល់លទ្ធភាពដល់ភាគីឲ្យប្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេច ដែលពួកគេមិនទទួលរងការប៉ះពាល់ដោយផ្ទាល់នោះទេ"[9] ហើយពួកគេសន្និដ្ឋានថា "ជាទូទៅ ដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរអាចត្រូវបានប្តឹងឧទ្ធរណ៍តែពីសំណាក់ភាគី ដែលបានស្នើសុំបើកកិច្ចស៊ើបសួរប៉ុណ្ណោះ"[10]។ បើមិនដូច្នោះទេ ភាគីនោះ"ត្រូវបង្ហាញថា ខ្លួនរងការប៉ះពាល់ពីដីកាសម្រេចដែលជាប់បណ្តឹងឧទ្ធរណ៍នោះ"[11]។

១១.កត្តានេះមិនមានចែងក្នុងអត្ថបទច្បាប់ជាធរមានទេ ហើយផ្ទុយនឹងពាក្យដែលមានចែងក្នុងវិធាន ៧៤។ លើសពីនេះទៀត ថ្វីបើអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "បញ្ជីដែលចែងក្នុងវិធាន ៧៤ ជាបញ្ជីចំហរ គឺគ្មានព្រំដែន" អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់លាស់ "ថ្វីបើមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ត្រូវតែយកការបកស្រាយយ៉ាងទូលំទូលាយនៃសិទ្ធិបុគ្គលត្រូវចោទក្នុងវិស័យឧទ្ធរណ៍ ដើម្បីធានាថា របៀបក្តីដឹកនាំក្នុងពេលស៊ើបអង្កេតត្រឹមត្រូវ និងមានយុត្តិធម៌ និងប្រឈមមុខ ដើម្បីរក្សាតុល្យភាពសិទ្ធិរបស់ភាគី"[12]។

១២.នៅក្នុងបញ្ហានេះ ត្រូវតែកំណត់យកការបកស្រាយយ៉ាងទូលំទូលាយក្នុងប្រយោជន៍នៃជនត្រូវចោទ

---

[8] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធិរិទ្ធ នួន ជា ខៀវ សំផន និងអៀង សារី ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំឲ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ ថ្ងៃទី១០ សីហា ២០០៩ ឯកសារតុលាការ D164/4/2 (បន្ទាប់ទៅនេះហៅថា "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ១០។

[9] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៩។

[10] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៨។

[11] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១០។

[12] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោកខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ កថាខណ្ឌ៣៦។

**ខ-លោក ខៀវ សំផន មានសិទ្ធិប្រើប្រាស់សិទ្ធិប្តឹងឧទ្ធរណ៍របស់គាត់យ៉ាងពេញលេញ និងដោយសេរី**

១៣.តាមយោបល់សហព្រះរាជអាជ្ញា ការបកស្រាយយ៉ាងតឹងរឹងលើវិធាន ៧៤ ដែលមានលក្ខណៈរឹតចង្អៀតក្នុងវិស័យច្បាប់ព្រហ្មទណ្ឌ "អាចធ្វើបានតែក្នុងទ្រឹស្តីតែប៉ុណ្ណោះ"[13] ហើយវាមិនច្បាស់ថាការបកស្រាយរបៀបនេះ មិនមែនជាគោលបំណងរបស់អ្នកសរសេរបទបញ្ជាផ្ទៃក្នុងនេះទេ[14]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ភាពជាក់ស្តែងអំពីការបកស្រាយប្រភេទនេះ "បណ្តាលឱ្យមានចំនួនបណ្តឹងឧទ្ធរណ៍កើនឡើង ដូច្នេះធ្វើឱ្យខូចប្រយោជន៍ (...) លើយុត្តិធម៌ និងប្រសិទ្ធិភាពនៃរបៀបក្តី"។[15]

១៤.ក្នុងបញ្ហានេះ គេត្រូវកត់សម្គាល់ថាពាក្យដែលប្រើក្នុងវិធានផ្ទៃក្នុងគឺជាពាក្យដែលគេប្រើនៅក្នុងក្រមរបៀបក្តីអាជ្ញា។ ក្រុមការពារក្តីមិនមានគម្រោងដើមនៃវិធានផ្ទៃក្នុងនោះទេ ប៉ុន្តែវារឹតតែច្បាស់ប្រសិនបើអ្នកសរសេរវិធានផ្ទៃក្នុងចង់កម្រិតសិទ្ធិជនត្រូវចោទក្នុងវិស័យឧទ្ធរណ៍នេះ និងចង់កែប្រែច្បាប់ដែលអនុវត្តលើចំណុចពិសេសនេះ អ្នកសរសេរវិធានផ្ទៃក្នុងនេះ គេមុខចាំសរសេរយ៉ាងច្បាស់លាស់។ ចំណុចខាងលើនេះបានបញ្ជាក់យ៉ាងពិតប្រាកដថា មិនអនុវត្តលើបញ្ហាឧទ្ធរណ៍នេះទេ។ ទោះបីយ៉ាងណាក៏ដោយ វាជាតួនាទីរបស់អង្គបុរេជំនុំជម្រះដែលត្រូវផ្តល់ការបកស្រាយលើវិធាននេះឱ្យបានទូលំទូលាយក្នុងផលប្រយោជន៍របស់ជនត្រូវចោទ ទៅតាមគោការណ៍ទូទៅនៃច្បាប់ជាធរមានក្នុងវិស័យនេះ។

១៥.ផ្ទុយទៅវិញ ជាថ្មីម្តងទៀត នៅក្រោមលេសភូតកុហកដើម្បីធានាសិទ្ធិរបស់លោក ខៀវ សំផន ឱ្យទទួលបាននូវរបៀបក្តីមួយដ៏មានប្រសិទ្ធិភាព និងយុត្តិធម៌ តាមពិតសហព្រះរាជអាជ្ញាស្នើឱ្យកម្រិតលទ្ធភាពជនត្រូវចោទឱ្យប្រើសិទ្ធិយ៉ាងពេញលេញ និងយ៉ាងសេរី ក្នុងពេលស៊ើបអង្កេត។ ដំណោះស្រាយនេះក៏ត្រូវប្រើប្រាស់ផងដែរ ដើម្បី "បិទទ្វាមិនឱ្យមានការរំលោភ"[16] ... ដែលការប្រើសិទ្ធិដើម្បីការពារខ្លួនរបស់ជនត្រូវចោទបានទាមទារ!

---

[13] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់(ចុងទំព័រ)លេខ ៦។

[14] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១០។

[15] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១០។

[16] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់(ចុងទំព័រ)លេខ ៦។

១៦.ទោះជាមានលក្ខណៈទូលាយក៏ដោយ ក៏ការបកស្រាយបែបនេះ ផ្ទុយនឹងកាតព្វកិច្ចរបស់អាជ្ញាធរតុលាការដែលជាអ្នកធានាឱ្យបានថា សិទ្ធិរបស់ជនត្រូវចោទមិនអត់ប្រយោជន៍ និងមិនមានលក្ខណៈបំភ័ន្ត។ ការបកស្រាយនេះក៏បានបង្ហាញឱ្យឃើញផងដែរ អំពីការមាក់ងាយមួយមកលើក្រុមការពារក្តី ដែលចេតនាទុច្ចរិតហាក់ដូចជាត្រូវបានសន្មតទុក។

១៧.តាមពិត វិបាកដ៏ត្រឹមត្រូវរបស់វិធាន ២១ នៃវិធានផ្ទៃក្នុង និងវិធាន ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មិនប្រាកដថា អង្គបុរេជំនុំជម្រះពិនិត្យមើលក្នុង "កាលៈទេសៈមួយចំនួន (...) បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយភាគីដ៏ទៃ ក្នុងករណីដែលភាគីទាំងនេះរងការប៉ះពាល់ដោយផ្ទាល់ពីដីកាសម្រេចមួយ"[17] ប៉ុន្តែអង្គបុរេជំនុំជម្រះត្រូវធ្វើយ៉ាងណា ដើម្បីឱ្យជនត្រូវចោទអាចប្រើប្រាស់សិទ្ធិរបស់គាត់ដែលមានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់ បានដោយពេញលេញ និងដោយសេរី។

## គ. ក្នុងករណីណាក៏ដោយ លោក ខៀវ សំផន រងការប៉ះពាល់ដោយផ្ទាល់ពីដីកាសម្រេចនេះ

១-ការចូលរួមដាក់ពាក្យសុំមិនអាចដាក់លក្ខខណ្ឌអំពីផលប្រយោជន៍ និងគុណសម្បត្តិក្នុងការធ្វើទេ

១៨.ការដែលលោក ខៀវ សំផន មិនបានចូលរួមក្នុង "សំណើដើមឱ្យស្វែងរកឱ្យមានការចាប់ផ្តើមកំណត់លើសម្ភារៈភស្តុតាងសម្រាប់ដោះបន្ទុកទាក់ទងនឹងភាគីដែលដាក់ពាក្យប្តឹង"[18] ដូចដែលសហព្រះរាជអាជ្ញាបានបន្ទោសលើគាត់ថាមិនមានការប៉ះពាល់លើលក្ខណៈសម្បត្តិ និងប្រយោជន៍ក្នុងការធ្វើទេ។ ផ្ទុយមកវិញ ប្រសិនបើចៅក្រមស៊ើបអង្កេតសម្រេចយល់ស្របតាមសំណើសុំរបស់ភាគី នោះក៏អនុវត្តលើលោក ខៀវ សំផន ផងដែរ លើកលែងតែគាត់ត្រូវបានដាក់ក្នុងជំហរផ្សេងមួយទៀតខុសពីម្ចាស់ពាក្យសុំ។ ក៏ប៉ុន្តែ ចំពោះសំណើសុំដែលបានលើកឡើងនេះ វាមិនមែនជាករណីផ្សេងនេះឡើយ។

---

[17] ចម្លើយរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨។

[18] ចម្លើយរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

១៩.តាមអង្គហេតុ មូលហេតុដែលលោក ខៀវ សំផន អាចចូលរួមបានយ៉ាងយឺតយ៉ាវក្នុងសំណើសុំនេះ គឺដោយសារបញ្ហានៃការអនុវត្តជាក់ស្តែងប៉ុណ្ណោះ៖ នៅថ្ងៃដាក់ឯកសារ សំណើសុំត្រូវបានធ្វើឡើងជាភាសាអង់គ្លេស និងបកប្រែជាភាសាខ្មែរប៉ុណ្ណោះ ហើយលោក ខៀវ សំផន មិនបានទទួលការជូនដំណឹងជាភាសាបារាំងទេ។ គាត់បានទទួលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបានបកប្រែជាភាសាបារាំង (ភាគខ្លះ) ជាមួយគ្នានឹងភាគីឯទៀត។ គាត់បានសម្រេចចិត្តគាំទ្រនីតិវិធី ហើយបានចុះហត្ថលេខាលើសារណាឧទ្ធរណ៍រួមដែលគាត់បានតម្កល់ជាភាសាខ្មែរ និងបារាំងក្នុងការិយាល័យក្រឡាបញ្ជី[19]។

២០.ដូច្នេះ ការិយាល័យសហព្រះរាជអាជ្ញាមិនត្រូវមានការងឿងឆ្ងល់ឡើយ៖ ក្រុមការពារក្តីលោក ខៀវ សំផន បន្តជំហររបស់ខ្លួនថា មិនអាចរួមចំណែកក្នុងរបៀបក្តីបាន លើកលែងតែមានឯកសារបកប្រែជាភាសាបារាំង។

២-ដីកាសម្រេចលើលានស៊ើបអង្កេត និងពាក់ព័ន្ធភាគីក្នុងនីតិវិធីក្តី

២១.ដូចដែលបានរំលឹកឡើងក្នុងសំណើសុំខាងដើមរបស់ក្រុមការពារក្តី "យើងអាចសន្និដ្ឋានបានថាមានឯកសារដោះបន្ទុក នៅក្នុងចំណោមឯកសារដែលសហព្រះរាជអាជ្ញាបានដាក់នៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ"[20]។ ដូច្នេះ ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលនៅក្នុងនោះពួកគាត់បានសម្រេចបដិសេធលើសំណើសុំរបស់ក្រុមការពារក្តី "ក្នុងការវិភាគពិនិត្យលើឯកសារទាំងនោះ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុក" បានប៉ះពាល់ដោយផ្ទាល់លើសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ហើយក៏ប៉ះពាល់ដល់ជនត្រូវចោទទាំងអស់រួមទាំងលោក ខៀវ សំផន ផងដែរ។

២២.វាប្រាកដណាស់ថា "កិច្ចស៊ើបអង្កេតដែលដឹកនាំដោយសហចៅក្រមស៊ើបអង្កេត គឺជាបញ្ហាចម្បងនៃនីតិវិធីចំពោះមុខអ.វ.ត.ក"[21] ហើយសេចក្តីសម្រេចណាដែលវិបាករបស់វាពាក់ព័ន្ធនឹងបញ្ហានេះក៏ប៉ះពាល់ដល់រូបលោក ខៀវ សំផន ដូចគ្នានឹងភាគីដ៏ទៃទៀតក្នុងនីតិវិធីផងដែរ។

---

[19] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ជាភាសាបារាំង ERN 355400-355416។

[20] សំណើរួមរបស់មេធាវីការពារក្តី សុំឲ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ លេខ ERN 00355938-0039559348 កថាខណ្ឌ១។

[21] សារណារបស់ក្រុមការពារក្តី កថាខណ្ឌ៨។

## អាស្រ័យហេតុនេះ

២៣.សហមេធាវីការពារក្តី សូមអង្គបុរេជំនុំជម្រះ មេត្តា៖

- យល់ស្របតាមលក្ខណៈគ្មានកម្រិតនៃសិទ្ធិប្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចទាំងអស់ដែលមានចែងក្នុងវិធាន ៧៤
- សម្រេចថា បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបើកកិច្ចស៊ើបអង្កេតឲ្យស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងបញ្ជីឯកសាររួម" គឺអាចទទួលយកបាន

## រក្សាសិទ្ធិកែប្រែគ្រប់បែបយ៉ាង
## និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| ២៤ សីហា ២០០៩ | លោក ស សូវាន<br>លោក Jacques VERGÈS | ភ្នំពេញ | 1. [signature]<br>P.O. 1. [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |